ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 04 / 2014
ម៉ោង (Time/Heure): 11:16
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យូរ ឱត្តារា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**
នួន ជា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE

00984135

E301/11

## ១. សេចក្តីផ្តើម

១. តាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ក្រុមមេធាវីការពារក្តីឱ្យជនជាប់ចោទ នួន ជា និង ខៀវ សំផន បានដាក់សារណាជាលាយលក្ខណ៍អក្សរនៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ ស្តីពីបញ្ហាសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការសំណុំរឿង ០០២/ ០២[១]។ សហព្រះរាជអាជ្ញាបានឆ្លើយតបនៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៤[២]។ នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្រចំនួនបីរូប គឺ វេជ្ជបណ្ឌិត Seena FAZEL វេជ្ជបណ្ឌិត CHAN Kin Ming និងវេជ្ជបណ្ឌិត ហួត លីនណា ("អ្នកជំនាញ") ដើម្បីពិនិត្យទៅលើជនជាប់ចោទ និងរៀបចំរបាយការណ៍រួមគ្នាមួយសម្រាប់ជនជាប់ចោទម្នាក់ៗ ("របាយការណ៍")[៣]។ របាយការណ៍ទាំងនេះត្រូវបានដាក់នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤[៤] ។

២. នាពេលនេះ អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចរបស់ខ្លួនលើសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ។ នៅក្នុងពេលដំណាលគ្នានេះ អង្គជំនុំជម្រះក៏នឹងចេញសេចក្តីសម្រេចមួយទៀត ស្តីពីសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមសវនាការផងដែរ[៥] ។

## ២. សារណា

[១] ចម្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងឱ្យដាក់សារណាទាក់ទងនឹងការពិនិត្យឡើងវិញលើសម្បទារបស់ នួន ជា ឡើងវិញ ឯកសារ E301/7 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ ("សំណើរបស់ នួន ជា")។ ព័ត៌មាននៃក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធនឹងសម្បទា និងបែបបទនៃការរៀបចំសវនាការ ឯកសារ E301/6 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ ("សំណើរបស់ ខៀវ សំផន")។

[២] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងសារណារបស់ នួន ជា និង ខៀវ សំផន ទាក់ទងទៅនឹងការកំណត់កាលបរិច្ឆេទសវនាការរបស់តុលាការ និងការពិនិត្យឡើងវិញអំពីសម្បទា ឯកសារ E301/8 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៤ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា")។

[៣] សេចក្តីសម្រេចស្តីពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ និងដីកាចាត់តាំងអ្នកជំនាញ ឯកសារ E301/10 ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ("ដីកាចាត់តាំងអ្នកជំនាញ")។

[៤] របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ នួន ជា ឯកសារ E301/10/6 ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ ("របាយការណ៍ នួន ជា")។ របាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រ ខៀវ សំផន ឯកសារ E301/10/7 ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤។

[៥] សេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទ ខៀវ សំផន ក្នុងការចូលរួមក្នុងសវនាការ ឯកសារ E301/12 ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤។

៣. មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យមានការវាយតម្លៃយ៉ាងល្អិតល្អន់មួយទៅលើស្ថានភាពសុខភាពរបស់ នួន ជា និងលទ្ធភាពរបស់គាត់ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីសវនាការ ដោយយោងទៅលើរោគសញ្ញាដែលជនជាប់ចោទ នួន ជា បានរាយការណ៍ និងស្ថានភាពចុះខ្សោយដែលបានបញ្ជាក់នៅក្នុងរបាយការណ៍វេជ្ជសាស្ត្រកន្លងមក[៦]។ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណើនេះ[៧]។ មេធាវីការពារក្តី ខៀវ សំផន មិនបានស្នើសុំការវាយតម្លៃជាក់លាក់ណាមួយលើបញ្ហាសម្បទាក្នុងការចូលរួមសវនាការរបស់ជនជាប់ចោទ ខៀវ សំផន នោះទេ ប៉ុន្តែបានកត់សម្គាល់ថា ខៀវ សំផន អាចចូលរួមនៅក្នុងការពិនិត្យសម្បទានេះបាន[៨]។

៤. ការវាយតម្លៃរបស់អ្នកជំនាញលើស្ថានភាពសុខភាពរបស់ជនជាប់ចោទទាំងពីរ ត្រូវបានធ្វើឡើងនៅក្នុងខែ មីនា ឆ្នាំ ២០១៤។ របាយការណ៍នៃការវាយតម្លៃនេះត្រូវបានផ្តល់ឱ្យភាគីទាំងអស់ ទោះបីមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈក្តី។ កន្លងមក អង្គជំនុំជម្រះបានអញ្ជើញភាគីទាំងអស់ឱ្យធ្វើការបញ្ជាក់ថាតើខ្លួនមានបំណងចង់ចូលរួមក្នុងសវនាការផ្ទាល់មាត់ ដើម្បីចោទសួរទៅអ្នក-ជំនាញស្តីពីរបាយការណ៍ទាំងនេះដែរឬទេ[៩]។ ភាគីទាំងអស់បានជូនដំណឹងមកអង្គជំនុំជម្រះវិញថា ខ្លួនមិនមានបំណងចង់ចូលរួមក្នុងសវនាការនេះទេ។ ហេតុដូច្នេះ សវនាការសម្រាប់គោលបំណងនេះមិនបានរៀបចំធ្វើនោះទេ។

៥. ទោះបីជានៅក្នុងសារណាជាលាយលក្ខណ៍អក្សររបស់ខ្លួន ក្រុមមេធាវីការពារក្តីទាំងពីរបានផ្តល់ការសង្កេតទៅលើបញ្ហាសុខភាពរបស់កូនក្តីខ្លួន ជាពិសេសទៅលើលទ្ធភាពរបស់ជនជាប់ចោទក្នុងការថ្លង់ស្មារតីក្នុងរយៈពេលវែងក៏ដោយ ក៏មិនមានភាគីណាមួយតវ៉ាដោយជាក់លាក់ថា ជនជាប់-ចោទណាមួយមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងសវនាការឡើយ។ បន្ទាប់ពីទទួលបានរបាយការណ៍របស់អ្នកជំនាញ គ្មានភាគីណាមួយបានស្នើសុំតាំងសំណួរទៅអ្នកជំនាញពីរបាយ-ការណ៍នេះ នោះទេ។

---

[៦] សំណើរបស់ នួន ជា កថាខណ្ឌ ១១, ១៥(ក)។

[៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥ ដល់ ១២។

[៨] សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៤។ នៅក្នុងសវនាការថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ មេធាវី ខៀវ សំផន បានបញ្ជាក់ថាជនជាប់ចោទរូបនេះមាន "សុខភាពល្អជាធម្មតា" និងបានលើកឡើងថា ការព្រួយបារម្ភដែលបានលើកឡើងដោយក្រុមមេធាវី នួន ជា អំពីស្ថានភាពសុខភាពរបស់ ខៀវ សំផន និង សមត្ថភាពចុះខ្សោយទៅៗ ដែលក្រុមមេធាវីនេះបានអះអាង មិនមានមូលដ្ឋានទេ៖ ប្រតិចារិក ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ទំព័រ ២៥។

[៩] ដីកាចាត់តាំងអ្នកជំនាញ កថាខណ្ឌ ១៦។

## ២. សំអាងហេតុ

៦. កន្លងមក អង្គជំនុំជម្រះបានកំណត់យកច្បាប់ជាធរមានស្តីពីបញ្ហាសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ។ ជារួម ជនជាប់ចោទត្រូវតែមានសមត្ថភាពអាចចូលរួមប្រកបដោយអត្ថន័យ ដែលអាចឲ្យជនជាប់ចោទអនុវត្តនូវសិទ្ធិរបស់ខ្លួនក្នុងការចូលរួមការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ នៅក្នុងកម្រិតមួយដែលគាត់អាចចូលរួមយ៉ាងមានប្រសិទ្ធភាពក្នុងការជំនុំជម្រះលើរូបគាត់ និងមានការយល់ដឹងពីចំណុចសំខាន់ៗនៃកិច្ចដំណើរការនីតិវិធី។ ក្នុងការធ្វើការវាយតម្លៃនេះ អង្គជំនុំជម្រះពិចារណាទៅលើរាល់ធាតុផ្សំទាំងអស់ និងកត្តានានា រួមទាំងភស្តុតាងដែលផ្តល់ដោយអ្នកជំនាញ ការសង្កេតផ្ទាល់របស់អង្គជំនុំជម្រះ បញ្ហាសុខភាពជាក់លាក់ណាមួយដែលអាចកើតមាន និងផលប៉ះពាល់លើសម្បទាជនជាប់ចោទដែលបណ្តាលមកពីបញ្ហាសុខភាពនេះ វិធានការជាក់ស្តែងនានាដែលមានសម្រាប់កាត់បន្ថយបច្ច័យអវិជ្ជមាននានាដោយសារការចុះខ្សោយសុខភាព និងករណីដែលជនជាប់ចោទមានមេធាវីការពារក្តី[១០]។

៧. អ្នកជំនាញបានពិនិត្យជនជាប់ចោទ នួន ជា អស់រយៈពេលពីរថ្ងៃជាប់ៗគ្នា គឺនៅថ្ងៃទី ២៤ និងទី ២៥ ខែ មីនា ឆ្នាំ ២០១៤ និងបានពិនិត្យលើរបាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍ដែលរៀបចំដោយវេជ្ជបណ្ឌិតប្រចាំនៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក[១១]។ អ្នកជំនាញបានសន្និដ្ឋានថា នួន ជា មានសភាព "ទន់ខ្សោយ" ប៉ុន្តែមានសុខភាពល្អធម្មតា បើគិតតាមវ័យ និងស្ថានភាពជំងឺប្រចាំកាយរបស់គាត់[១២]។ អ្នកជំនាញបានធ្វើរោគវិនិច្ឆ័យលើផ្នែករាងកាយពីរកន្លែងគឺ [redacted] ប៉ុន្តែបានសន្និដ្ឋានថា អាការៈទាំងពីរនេះមិនប៉ះពាល់ដល់

---

[១០] *សូមមើល* សេចក្តីសម្រេចលើសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ និងលើសំណើរបស់ក្រុមមេធាវីការពារក្តីសុំចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្របន្ថែម ឯកសារ E115/3 ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ ១៤ ដល់ ១៨។ សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ឯកសារ E138 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ ២៥ ដល់ ៣០។ សេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E138/1/10 ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ កថាខណ្ឌ ១៨។ សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ឯកសារ E238/9 ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ១៨។ សេចក្តីសម្រេចលើកទីពីរលើសម្បទា និងបញ្ហាស្មារតីរបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ឯកសារ E256/5 ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ១៣ ដល់ ១៤។

[១១] របាយការណ៍ នួន ជា កថាខណ្ឌ ៣, ១៩។

[១២] របាយការណ៍ នួន ជា កថាខណ្ឌ ១៥, ៣៨។

សម្បទាក្នុងការចូលរួមសវនាការរបស់គាត់នោះទេ[១៣]។ អ្នកជំនាញបានផ្តល់ការណែនាំនូវវិធានការជាក់ស្តែងផ្សេងៗដើម្បីកាត់បន្ថយការឈឺចង្កេះរបស់គាត់ នៅពេលអង្គុយក្នុងសាលសវនាការ[១៤]។ [redacted][១៥]។ អ្នកជំនាញបានសន្និដ្ឋានថា ជនជាប់ចោទ នួន ជា មិនមានជំងឺផ្លូវចិត្តទេ និងមិនឃើញមានភស្តុតាងអំពីការចុះខ្សោយខាងសតិបញ្ញាស្មារតី ដែលខុសពីធម្មតានៃបញ្ញាស្មារតីរបស់មនុស្សដែលមានវ័យ និងសាវតារដូចគាត់នោះដែរ[១៦]។ អ្នកជំនាញយល់ឃើញថា គាត់អាច "ចូលរួមសវនាការដែលមានរយៈពេលពេញលេញ និងពេលវេលាសម្រាកជាធម្មតាទៅតាមកាលវិភាគរបស់តុលាការ"[១៧]។

៨. អ្នកជំនាញបានវាយតម្លៃជនជាប់ចោទ នួន ជា ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យទាំងប្រាំពីរដែលត្រូវបានកំណត់ដោយតុលាការកំពូល ICTY ក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Strugar* សម្រាប់ពិនិត្យមើលលទ្ធភាពក្នុងការតតាំងក្តី និងចូលរួមសវនាការរបស់ជនជាប់ចោទ។ អ្នកជំនាញបានរកឃើញថា នួន ជា បានបំពេញគ្រប់លក្ខណៈវិនិច្ឆ័យទាំងនេះ[១៨]។

៩. បន្ទាប់ពីបានពិនិត្យរបាយការណ៍របស់អ្នកជំនាញ និងរបាយណ៍ការវេជ្ជសាស្ត្រប្រចាំសប្តាហ៍ទាក់ទងនឹងជនជាប់ចោទ នួន ជា អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា នួន ជា មិនមានបញ្ហាផ្នែករាងកាយ ឬបញ្ញាស្មារតី ដែលធ្វើឱ្យគាត់មិនអាចចូលរួមប្រកបដោយអត្ថន័យក្នុងកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០២ ឡើយ។

១០. អង្គជំនុំជម្រះនឹងនៅតែបន្តចាត់វិធានការជាក់ស្តែងដូចជា ការអនុញ្ញាតឱ្យជនជាប់ចោទចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ដោយអនុលោមតាមវិធាន ៨១(៥) នៃវិធានផ្ទៃក្នុង នៅពេលណាដែលការធ្វើបែបនេះ

---

[១៣] របាយការណ៍ នួន ជា កថាខណ្ឌ ១៦, ១៧, ៣៨។

[១៤] របាយការណ៍ នួន ជា កថាខណ្ឌ ៣៩។

[១៥] របាយការណ៍ នួន ជា កថាខណ្ឌ ១២ (ខ)។

[១៦] របាយការណ៍ នួន ជា កថាខណ្ឌ ៤១។

[១៧] របាយការណ៍ នួន ជា កថាខណ្ឌ ៤០។

[១៨] របាយការណ៍ នួន ជា កថាខណ្ឌ ២៩ ដល់ ៣៦។ *សូមមើល* រឿងក្តី ព្រះរាជអាជ្ញា ទល់នឹង Strugar តុលាការកំពូល ICTY (IT-01-42-A) សាលដីកា ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨។

ជាការចាំបាច់ដើម្បីដោះស្រាយការលំបាកនានាដែលជនជាប់ចោទមានក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការ។ ជាពិសេស តាមអនុសាសន៍របស់អ្នកជំនាញ អង្គជំនុំជម្រះនឹងនៅតែបន្តធានាថា ជនជាប់ចោទ នួន ជា នឹងត្រូវនាំមកកាន់សាលសវនាការតាមរយៈកៅអីរុញ និងអនុញ្ញាតឱ្យគាត់អង្គុយនៅលើកៅអីរុញនេះនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការ។ អង្គជំនុំជម្រះនឹងណែនាំឱ្យអង្គភាពពេទ្យ មន្ទីរឃុំឃាំង និងផ្នែករដ្ឋបាលតុលាការនៃ អ.វ.ត.ក អនុវត្តតាមការណែនាំផ្នែកវេជ្ជសាស្ត្រ ការព្យាបាល និងរបបអាហារ ដែលមាននៅក្នុងរបាយការណ៍របស់អ្នកជំនាញ។ អង្គជំនុំជម្រះយល់ឃើញថា វិធានការទាំងនេះនឹងជួយកាត់បន្ថយផលប៉ះពាល់ដែលអាចកើតមាន បណ្ដាលមកពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ ទៅលើលទ្ធភាពរបស់គាត់ក្នុងការចូលរួមសវនាការ។

១១. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការធ្វើតេស្តទៅលើផ្នែកសតិបញ្ញាស្មារតីពីសំណាក់អ្នកជំនាញបានបង្ហាញថា ជនជាប់ចោទ នួន ជា ទទួលបានពិន្ទុធម្មតាសម្រាប់មនុស្សវ័យដូចគាត់[១៩]។ ក្នុងការឆ្លើយតបទៅនឹងសំណួរដែលត្រូវបានរៀបរៀងឡើង សម្រាប់ធ្វើតេស្តលើសមត្ថភាពចងចាំរយៈពេលវែងរបស់គាត់ គាត់បានផ្ដល់ចម្លើយត្រូវគ្នាទៅនឹងចម្លើយដែលគាត់បានផ្ដល់ក្នុងអំឡុងពេលពិនិត្យសុខភាពលើកមុនៗ[២០]។ របាយការណ៍អ្នកជំនាញបានបញ្ជាក់ថា នួន ជា អាចផ្ដល់ស្មារតីបានពេញលេញក្នុងអំឡុងពេលពិនិត្យសុខភាព ដែលការពិនិត្យវែងជាងគេមានរយៈពេល ៨៥ នាទី[២១]។ អង្គជំនុំជម្រះជឿថា ជនជាប់ចោទ នួន ជា មានសមត្ថភាពខាងផ្នែកសតិបញ្ញាស្មារតីដែលជាលក្ខខណ្ឌតម្រូវសម្រាប់ចូលរួមក្នុងការការពារខ្លួនរបស់គាត់។

១២. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ជនជាប់ចោទ នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ដោយអនុលោមតាមបទដ្ឋានគតិយុត្តិដូចបានកំណត់ខាងលើ។

១៣. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មានសំណើដែលនៅមិនទាន់ត្រូវបានដោះស្រាយមួយចំនួនពីភាគីនានាទាក់ទងនឹងការកែប្រែកាលវិភាគសវនាការដែលមានស្រាប់របស់អង្គជំនុំជម្រះ[២២]។ អង្គ-

---

[១៩] របាយការណ៍ នួន ជា កថាខណ្ឌ ២៦។

[២០] របាយការណ៍ នួន ជា កថាខណ្ឌ ២៤ ដល់ ២៥។

[២១] របាយការណ៍ នួន ជា កថាខណ្ឌ ១១(ឈ) , ២២, ៤១។

[២២] សំណើរបស់ នួន ជា កថាខណ្ឌ ១៣ ដល់ ១៥។ សំណើរបស់ ខៀវ សំផន កថាខណ្ឌ ៥។ ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣ ដល់ ៤, ១៣។

ជំនុំជម្រះយល់ឃើញថា មិនទាន់ដល់ពេលត្រូវដោះស្រាយសំណើទាំងនេះនៅឡើយទេនៅខណៈពេលនេះ ប៉ុន្តែអង្គជំនុំជម្រះនឹងពិចារណាលើសំណើរបស់ភាគី នៅពេលធ្វើការកំណត់កាលវិភាគសម្រាប់សវនាការដេញដោលលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ ដែលការកំណត់កាលវិភាគនេះនឹងត្រូវធ្វើឱ្យបានឆាប់មុនពេលចាប់ផ្តើមសវនាការលើភ័ស្តុតាង។

**ផ្អែកលើសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះ÷**

**សម្រេចតម្កល់** ការសម្រេចពីមុនដែលថា ជនជាប់ចោទ នួន ជា មានសមត្ថភាពអាចចូលរួមសវនាការប្រកបដោយអត្ថន័យក្នុងការការពារខ្លួនគាត់ ហេតុដូច្នេះ គាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។

**ណែនាំឲ្យ** អង្គភាពពេទ្យ មន្ទីរឃុំឃាំង និងផ្នែករដ្ឋបាលតុលាការនៃ អ.វ.ត.ក ដោយមានការគាំទ្រពីការិយាល័យរដ្ឋបាល អនុវត្តអនុសាសន៍របស់អ្នកជំនាញដែលមាននៅក្នុងកថាខណ្ឌ ១៤, ១៥, ៣៨ និង ៣៩ នៃរបាយការណ៍របស់អ្នកជំនាញទាក់ទងនឹង នួន ជា។

ភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C * C.E.T.C.

និល ណុន